**អង្គការ អភិវឌ្ឍន៍សហគមន៍ជនបទ និង បរិស្ថាន(អា-សេ-ដូ)**

**Rural Community and Environment Development Organization (RCEDO)**
Contract Address: Road 1,1/2; Kampong Svay Commune, Serei Sophorn Town,
Banteay Meanchey Province, Tel: 054 958 942 / 054 710 446 / 012 284 345

# របាយការណ៍វឌ្ឍនភាពគម្រោងប្រចាំឆ្នាំ ២០១៨ របស់អង្គការ អាសេដូ

### រយៈពេលនៃរបាយការណ៍
### ០១ មិនា ឆ្នាំ ២០១៨ ដល់ ៣០ ធ្នូ ឆ្នាំ ២០១៨

| | |
|---|---|
| **ឈ្មោះគម្រោង** | ពង្រឹងសមត្ថភាពសង្គមស៊ីវិលក្នុង ខេត្តឧត្តរមានជ័យ |
| **គាំទ្រថវិកា** | អង្គការ ADDA/ Denmark.<br>អង្គការ SNV(CHAIN 2) |
| **អង្គការអនុវត្តន៍** | អង្គការអភិវឌ្ឍន៍សហគមន៍ជនបទ និង បរិស្ថាន (អាសេដូ)<br>Rural Community and Environment Development Org (RCEDO). |
| **ថវិកាសរុបរួម** | US$ ៤៩, ៦០០.០០ |
| **រយៈពេលនៃគម្រោង** | ០១ មិនា ឆ្នាំ ២០១៨ ដល់ ៣០ ធ្នូ ឆ្នាំ២០១៨ |
| **ថ្ងៃរៀបចំរបាយការណ៍** | ៣០ ធ្នូ ឆ្នាំ ២០១៨ |

## ១-ប្រវត្តិគម្រោង

### ១-១ គម្រោងពង្រឹងសមត្ថភាពសង្គមស៊ីវិល ក្នុង ខេត្តឧត្តរមានជ័យ (CISOM)

គម្រោង ស៊ីសោម ជាគម្រោងមួយដែលផ្តល់ឱកាសអោយអង្គការក្នុងស្រុក៥ គឺ អង្គការ KBA, RCEDO, CIDO, READA និង ADDA បានអនុវត្តគម្រោងរួមគ្នា ក្នុងខេត្តឧត្តរមានជ័យ ដែលមានការគាំទ្រថវិកាពីប្រទេស Denmark ។ គម្រោងនេះ គឺ ជាគម្រោងឆ្នាំទី ២ ជំហ៊ានទី២(២០១៧-២០១៩) ។ អង្គការ RCEDO បាននឹងកំពង់អនុវត្តគម្រោងនេះនៅលើ ២៧ ភូមិ ៦ឃុំ និង ២ ស្រុក( គឺ ស្រុកចុងកាល់ និង សំរោង) នៃ ខេត្តឧត្តរមានជ័យ ។

គោលបំណងសំខាន់ នៃ គម្រោង គឺ ដើម្បីកាត់បន្ថយភាពក្រីក្រ និងភាពអត់ឃ្លានរបស់ប្រជាជនក្រីក្រក្នុងខេត្តឧត្តរមានជ័យ តាមរយៈការបង្កើនការហូប /ឬប្រាក់ចំណូលយ៉ាងហោចណាស់ ៣០%

ពីការលក់បន្លែ ចិញ្ចឹមសត្វខ្នាតតូច និង អាជីវកម្មខ្នាតតូចរបស់សហគមន៏កសិកម្ម ។ គម្រោងនេះ នឹងជួយដល់ប្រជាជនក្រីក្រទទួលផលផ្ទាល់ចំនួន ១០០០គ្រួសារ តាមរយៈការចូលរួមរៀនសូត្រពីសាលាស្រែកសិករ ៣សាលា(ការដាំបន្លែ និង ចិញ្ចឹមសត្វ), ការបង្កើតក្រុមជួយខ្លួនឯងចំនួនថ្មី៩ រួមទាំងពង្រឹងក្រុមចាស់២៧ និង រៀបចំបង្កើតសហគមន៏កសិកម្មចំនួន៣ ។ អ្នកទទួលផលប្រយោលពីគម្រោងចំនួន៦០០០គ្រួសារ ។

## ២-ភ្នាក់ងារអនុវត្តគម្រោង:

គម្រោងនេះគឺអនុវត្តដោយអង្គការ អាសេដូ (RCEDO) ប្រចាំខេត្តបន្ទាយមានជ័យ និង សាខាឧត្តរមានជ័យ។

## ៣- តំបន់គោលដៅគម្រោង

| ល.រ. | ស្រុក. ក្រុង | ឃុំ. សង្កាត់ | ចំនួនភូមិ | ចំនួន ប្រជាពលរដ្ឋសរុប | | សរុបរួម |
|---|---|---|---|---|---|---|
| | | | | ប្រុស | ស្រី | |
| ១ | ក្រុង សំរោង | សំរោង | ០៥ | ២០៩៦ | ២០៦៥ | ៤១៦១ |
| | | កូនគ្រៀល | ១៧ | ១៩៧៩ | ២០១០ | ៣៩៨៩ |
| | | បន្សាយរាក់ | ០២ | ៩៩៣ | ៨៨៩ | ១៨៨២ |
| | | ត្របែក | ០៤ | ៦៤៩ | ៦៩០ | ១៣៣៩ |
| ២ | ចុងកាល់ | ពង្រ | ០៥ | ២១៦៤ | ២១១៤ | ៤២៧៨ |
| | | ចុងកាល់ | ០៤ | ១៨៤២ | ១៥៦០ | ៣៤០២ |
| | | ជើងទាន | ០៤ | ១១៨៤ | ១១៦២ | ២៣៤៦ |
| | | ក្រសាំង | ០៦ | ៣៦៨៤ | ៣៥៤៣ | ៧២២៧ |
| | សរុបខេត្តឧត្តរមានជ័យ | ៨ ឃុំ | ៤៧ | ១៤៥៩១ | ១៤០៣៣ | ២៨៦២៤ |

## ៤- សកម្មភាព និង លទ្ធផល សំរេចបានឆ្នាំ២០១៨

### ៤-១ គម្រោងពង្រឹងសមត្ថភាពសង្គមស៊ីវិល ក្នុង ខេត្តឧត្តរមានជ័យ (CISOM)

១- បានរៀបចំមហាសន្និបាតសហគមន៍បានចំនួន ៣សហគមន៍ ( សហគមន៍ គោកឈូកសាមគ្គី គោកភ្លុកអភិវឌ្ឍន៍បីភូមិ និង សហគមន៍ ចុងកាល់អភិវឌ្ឍន៍) កសិរចូលរួមសរុប ២៨៥នាក់ ស្រី២០៣នាក់

២- បានរៀបចំ និងសម្របសម្រួលការធ្វើផែនការវិនិយោគថ្នាក់ភូមិបាន ១៦ ភូមិ មានកសិករចូលរួម ២២៩នាក់ ស្រី ១៧០នាក់

៣- បានពង្រឹងសមត្ថភាព និងចុះតាមដានក្រុមជួយខ្លួនឯង និង សន្សំប្រាក់របស់សមជិកបានចំនួន ៣៦ ក្រុម មានសមាជិកសរុប ៨០៦នាក់ (ស្រី ៦៧៩នាក់) ដែលមានដើមទុនចរាចរក្នុងមូលដ្ឋានមានដើមទុនសរុប៣២៩,១៥៩.៥០០រៀល និងបានផ្តល់សមាជិកកំចីអស់២៦៦,៦៦៧,៨០០រៀល(៨០%) ។

៤- បានពង្រឹងសមត្ថភាពសហគមន៏កសិកម្មចំនួន ៣ មានសមាជិកសរុប ៣០៤ នាក់(ស្រី២៣២នាក់) ក្នុង ៣ឃុំ គឺ កូនក្រៀល, ចុងកាល់ និង ក្រសាំង ក្នុងខេត្តឧត្តរមានជ័យ ដែលមានហ៊ុនសរុប ៤៣៣ហ៊ុន និងដើមទុនសរុប ១១៩,៤១៩,៦០០រៀល ដើម្បីធ្វើអាជីវកម្មឥណទានកសិកម្ម (សាច់ប្រាក់) និង ទិញលក់សំភារៈកសិកម្ម (ឥណទានជី) ។

៥-បណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់គណកម្មការសហគមន៍និងអ្នកជំនាញសហគមន៍លើការកត់ត្រាបញ្ជីស្នាមការធ្វើផែនការអាជីវកម្ម បានចំនួន៣ វគ្គ មានអ្នកចូលរួមសរុម ១០៥នាក់

៦- បណ្តុះបណ្តាលវគ្គខ្លីៗ ស្តីពីការដាំបន្លែ ដំឡូងមី ស្ត្រីភាពជាដឹកនាំក្រុម និងដំណាំស្រូវ បានចំនួន ២១ភូមិ លើ៣ឃុំ គឺ ឃុំចុងកាល់ សំរោង កូនក្រៀល ខេត្ត ឧត្តរមានជ័យ ។

៧- បានចុះពិនិត្យតាមដាន និង ពង្រឹងសមត្ថភាពដល់គណៈកម្មការធនាគារស្រូវចំនួន ២ភូមិ លើ០២ឃុំ គឺសំរោង និង កូនក្រៀលលើការកត់ត្រាបញ្ជី ការគ្រប់គ្រងទុន និងប្រមូលទុនស្រូវពីសមាជិក។

៨- ចូលរួមគាំទ្រការរៀបចំផែនការវិនិយោគភូមិឃុំ និង ស្រុកក្នុងតំបន់គោលដៅចំនួន ៦ ឃុំ លើ២ស្រុក។

## ៤-២ គម្រោងបន្លែ ផ្លែឈើកម្ពុជា (ឈេន/CHAIN) ក្នុងខេត្តឧត្តរមានជ័យ

១- ប្រជុំផ្សព្វផ្សាយភូមិដើម្បីបង្កើតជាក្រុមកសិករដាំបន្លែ បានចំនួន ២០ ភូមិ ស្មើ៣៨ លើក មានអ្នកចូលរួមសរុម ៩៦២ នាក់ ស្រី ៦៨២

២- ចងក្រងក្រុមដាំបន្លែបានចំនួន ១៥ក្រុម មានអ្នកចូលរួមសរុប ៣៥៦ នាក់ ស្រី ២៥៣ នាក់

៣- បណ្តុះបណ្តាលបច្ចេកទេសដាំបន្លែដល់ក្រុមពាក់កណ្តាលអាជីព បាន១៤ ភូមិ មានអ្នកចូលរួមសរុប ៣២៦ នាក់ ស្រី ២៤២

៤- បណ្តុះបណ្តាលបច្ចេកទេសដាំបន្លែ បាន២៩ ភូមិ ស្មើ ៧៨ លើក មានអ្នកចូលរួមសរុប ៣២៦នាក់ ស្រី២៤២ នាក់

៥- បណ្តុះបណ្តាលសាលាអាជីវកម្ម បានចំនួន១៤ ភូមិ ស្មើ៤១លើក មានអ្នកចូលរួម ៤៨៧ នាក់ ស្រី ៣៦៨នាក់

៦- ចងក្រងក្រុមបណ្តុំអាជីវកម្ម បានចំនួន៣ ភូមិ មានសមាជិក ៣៥ នាក់

៧- ចុះសម្ភាសន៍ក្រុមកសិករគោលដៅស្តីពីការវាយតម្លៃក្រុម បាន១៩ ក្រុម

## ៥- របាយការណ៍ថវិកាចំណាយឆ្នាំ២០១៨

(មើលរបាយការណ៏ភ្ជាប់ខាងក្រោម)

## ៦-បញ្ហាប្រឈម

- ការចូលរួមប្រជុំរបស់សមាជិកក្រុមថយចុះ ដោយសារចំណាកស្រុកទៅថៃ និងទៅធ្វើចំការឆ្ងាយពីផ្ទះ
- ពិបាកក្នុងការប្រមូលប្រជាពលរដ្ឋឲ្យចូលរួមប្រជុំវគ្គបណ្តុះបណ្តាល
- អាជ្ញាធរភូមិឃុំមួយចំនួនមិនសូវចូលរួមបានល្អ ព្រោះជាប់រវល់ ការងារគ្រឹះរបស់ពួកគាត់
- ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកំរិត
- ជួបគ្រោះធម្មជាតិក្នុងឃុំគោលដៅ ដូចជារាំងស្ងួត និង ទឹកជំនន់ ២០១៧
- ប្រជាពលរដ្ឋមួយចំនួតូចមិនឆន្ទះក្នុងការផ្លាស់ប្តូរទំលាប់នៃការការដាំបន្លែ និងមិនដាំបន្លែ

## ៧-ឱកាស:

- មានការគាំទ្រពីអាជ្ញាធរមូលដ្ឋាននៅពេលអនុវត្តន៍កម្មវិធី និង ជួយសម្របសម្រួលដល់បុគ្គលិកអង្គការ
- ប្រជាពលរដ្ឋមានការចូលរួម និង គាំទ្រគម្រោងអង្គការទាំងពីរ
- គម្រោងមានគោលដៅស្រប នឹង គោលនយោបាយ និង យុទ្ធសាស្រ្តរបស់រដ្ឋាភិបាល
- មានការគាំទ្រមូលនិធិពីអង្គការការីតាសស្វ៊ីស និងពី Denmark រយះពេលវែង (៣ឆ្នាំបន្ត)

## ៨- ផែនការអនុវត្តឆ្នាំ ២០១៩

- ចាប់ផ្តល់អនុវត្តគម្រោងថ្មី គឺ គម្រោងបន្លែផ្លែឈើកម្ពុជាលើ២៩ ក្រុមកសិករក្នុងខេត្តឧត្តរមានជ័យ ចាប់ពីខែ មិនាដល់ ធ្នូ ២០១៩ ។
- ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍(ការគ្រប់គ្រងបញ្ជីស្នាម,ការគ្រប់គ្រងសហគមន៍ ការស្វែងរកមតិគាំទ្រតាមផ្លូវច្បាប់)
- វគ្គបណ្តុះបណ្តាលស្តីពីការដឹកនាំក្រុម,ការគ្រប់គ្រងទុន,ជំនួញខ្នាតតូច, និង បច្ចេកទេសកសិកម្ម។
- ធ្វើមហាសន្និបាតសហគមន៍កសិកម្ម ៣ ។
- បិទគម្រោងចាស់(គម្រោងស៊ីសោម) និងបើកគម្រោងថ្មី (គម្រោង អាក់សូ)

**ធ្វើនៅបន្ទាយមានជ័យថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១៩**

រៀបចំដោយក្រុមការងារអង្គការ អាសេដូ

**ហត្ថលេខាប្រធានអង្គការ**

________________________

**លោក សំ សេរីវឌ្ឍនា**

Annex 2: Photos of CISOM Project Activities in Oddar Meanchey Province.

## ១). សកម្មភាពរៀនសូត្ររបស់កសិករពី សាលាស្រែកសិករលើបន្លែ

- កសិករបានចូលរៀនហើយយកទៅអនុវត្តតាមច្ចេកទេសដែលបានផ្តល់អោយ
- កសិករបានយល់ដឹងពីបច្ចេកទេសការទំនាក់ទំនងទីផ្សារអ្នកប្រមូលទិញបន្លែនិងអ្នកផ្គត់ផ្គង់សម្ភារៈកសិកម្ម
- បានចងក្រងក្រុមអ្នកផលិត និងអ្នកប្រមូលទិញ
-






## ២). សកម្មភាពរៀនសូត្ររបស់កសិករពីក្រុមជួយខ្លួនឯង និងអនុវត្តសហគមន៍កសិកម្ម






### ៣). សកម្មភាពរៀនសូត្ររបស់កសិករពី សន្និបាតសហគមន៍កសិកម្មប្រចាំឆ្នាំ ២០១៨

- យល់ដឹងពីរបៀបយុទ្ធនាកាផ្សព្វផ្សាយដើម្បីស្វែងរកសមាជិកថ្មីចូលក្នុងសហគមន៍
- យល់ពីរបៀបបិទបញ្ជី របៀបចែកភាគលាភ ដល់សមាជិក
- យល់ដឹងពីរបៀបរៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ




